# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ០១៧ សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារធ្វើការសិក្សា ស្រាវជ្រាវច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល។

### សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងារធ្វើការសិក្សា ស្រាវជ្រាវច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-សម្តេចក្រឡាហោម | **ស ខេង** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ប្រធាន |
| ២-ឯកឧត្តម | **ប៊ិន ឈិន** | ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣-ឯកឧត្តម | **អង្គ វង្សវឌ្ឍានា** | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៤-ឯកឧត្តម | **ពេជ្រ ប៊ុនធិន** | រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ | អនុប្រធាន |
| ៥-ឯកឧត្តម | **ឆេង សារឿន** | រដ្ឋលេខាធិការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ៦-ឯកឧត្តម | **សក់ សេដ្ឋា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៧-ឯកឧត្តម | **កើត រិទ្ធ** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ៨-ឯកឧត្តម | **ជូ វិចិត្រ** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៩-ឯកឧត្តម | **ឡាំ ជា** | អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១០-ឯកឧត្តម | **ម៉ាន់ ចំរើន** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |

www.pheakdeylaw.com

| | | | |
|---|---|---|---|
| ១១-ឯកឧត្តម | **ម៉ុន ហុន** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១២-ឯកឧត្តម | **លី ច័ន្ទតុលា** | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៣- ឯកឧត្តម | **ស៊ា ម៉ៅ** | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៤- ឯកឧត្តម | **សំ រិទ្ធី** | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៥-ឯកឧត្តម | **ផន ស៊ីន** | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៦-ឯកឧត្តម | **ប្រាក់ សំអឿន** | អគ្គនាយករដ្ឋបាលក្រសួងមហាផ្ទៃ | សមាជិក |
| ១៧-ឯកឧត្តម | **គង់ ទីលីន** | ទីប្រឹក្សាសម្ដេចក្រឡាហោម ស ខេង | សមាជិក |
| ១៨-ឯកឧត្តម | **ហ៊ីន យុទនា** | អនុប្រធានក្រុមប្រឹក្សានីតិកម្ម នៃក្រសួងមហាផ្ទៃ | សមាជិក |
| ១៩-លោក | **តាន់ សំណាង** | ប្រធាននាយកដ្ឋានក្រសួងមហាផ្ទៃ | សមាជិក។ |

**ប្រការ ២.**_

ក្រុមការងារនេះ មានភារកិច្ចជាសេនាធិការជូន សម្ដេចតេជោនាយករដ្ឋមន្ត្រី ក្នុងការសិក្សាស្រាវជ្រាវ ផ្ដួចផ្ដើមអំពីជម្រើសនានាក្នុងការកែសម្រួលច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី តាមការចាំបាច់។

**ប្រការ ៣.**_

ក្នុងការអនុវត្តភារកិច្ចដូចមានចែងក្នុងប្រការ២ខាងលើ ក្រុមការងារនេះអាចធ្វើការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ តាមការចាំបាច់។

**ប្រការ ៤.**_

ក្រុមការងារនេះ អាចបង្កើតក្រុមលេខាធិការ ដើម្បីជួយកិច្ចការរបស់ខ្លួន តាមការចាំបាច់។

ក្រុមការងារនេះ មានសិទ្ធិប្រើប្រាស់ត្រា និងថវិការបស់ក្រសួងមហាផ្ទៃ។

**ប្រការ ៥.**_

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ១២ កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>

-ទីស្ដីការគណៈរដ្ឋមន្ត្រី

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-ដូចប្រការ៥

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com